NATIONAL BOWELCANCER SCREENING PROGRAM

Australian Government

<Date> លេខអត្តសញ្ញាណៈ <Consumer ID>

<Participant Given Name> < Participant Family Name >
<Preferred Mailing Address>
<Preferred Mailing Address >
<LOCALITY> <STATE> <POSTCODE>

ជូនចំពោះ <Participant Given Name> < Participant Family Name >

តើលោកអ្នកដឹងឬទេថា មានជនជាតិអូស្ត្រាលីចំនួនប្រហែលជា៨០នាក់បានស្លាប់ក្នុងមួយសប្តាហ៍ៗ ដោយសារជម្ងឺមហារីកពោះវៀន? ជម្ងឺមហារីកពោះវៀន គឺជាជម្ងឺមហារីកមួយក្នុងចំណោមជម្ងឺមហារីកទូទៅភាគច្រើននៅក្នុងប្រទេសអូស្ត្រាលី ជាពិសេសចំពោះមនុស្សដែលមានអាយុលើសពី៥០ឆ្នាំ។ ដំណឹងល្អគឺថាមានតេស្តយ៉ាងសាមញ្ញមួយដែលលោកអ្នកអាចធ្វើនៅក្នុងផ្ទះរបស់លោកអ្នកដោយខ្លួនឯង ដែលអាចជួយឲ្យរកឃើញនូវរោគសញ្ញាពីដំបូងនៃជម្ងឺមហារីកពោះវៀន។

តេស្តនេះអាចរកឃើញចំនួនឈាមដ៏តិចតួចនៅក្នុងលាមករបស់លោកអ្នក។ នេះអាចជារោគសញ្ញានៃភាពមិនប្រក្រតី ឬជម្ងឺមហារីកពោះវៀន ហើយប្រសិនបើរកឃើញនៅក្នុងដំណាក់កាលពីដំបូង វាអាចងាយស្រួល និងមានជោគជ័យក្នុងការព្យាបាល។

រដ្ឋាភិបាលអូស្ត្រាលីបានណែនាំឲ្យមានកម្មវិធីជាតិលើការពិនិត្យរកមើលជម្ងឺមហារីកពោះវៀន សំរាប់មនុស្សអាយុ៥០ឆ្នាំ ៥៥ឆ្នាំ និង៦៥ឆ្នាំ រវាងខែមករា ឆ្នាំ២០០៨ និងខែធ្នូ ឆ្នាំ២០១០ ដើម្បីជួយកាត់បន្ថយនូវចំនួនជនជាតិអូស្ត្រាលីដែលស្លាប់ក្នុងមួយឆ្នាំៗដោយសារជម្ងឺមហារីកពោះវៀន។

កញ្ចប់នៃការអញ្ជើញដែលមានរួមទាំងគ្រឿងប្រដាប់សំរាប់ធ្វើតេស្ត ជាមួយនិងសេចក្តីណែនាំ និងកូនសៀវភៅព័ត៌មានដែលនឹងផ្ញើជូនលោកអ្នកក្នុងអម្លុងពេល២ ឬ៣សប្តាហ៍ខាងមុខនេះ។ ការធ្វើតេស្តគឺឥតគិតថ្លៃទេ ហើយការធ្វើតេស្តនឹងចំណាយពេលត្រឹមតែ២-៣នាទីប៉ុណ្ណោះ ចំនួនពីរលើកខុសៗគ្នា។ លទ្ធផលនៃការធ្វើតេស្តនឹងត្រូវបានរក្សាទុកយ៉ាងសម្ងាត់សំរាប់លោកអ្នក ហើយប្រសិនបើបានជ្រើសតាំង គឺវេជ្ជបណ្ឌិតរបស់លោកអ្នក។

ការរៀបចំសម្រួលពិសេសត្រូវបានដាក់នៅនឹងកន្លែង ដើម្បីឲ្យអ្នកកាន់បញ្ជីជ្រើសរើសឈ្មោះរបស់លោកអ្នកចេញពីកំណត់ត្រាណាមួយក៏បាន គឺពីកំណត់ត្រាការចុះឈ្មោះសំរាប់មេឌីឃែរ ឬសំណុំរឿងការចុះឈ្មោះនៅក្រសួងកិច្ចការអតីតយុទ្ធជនដើម្បីចេញនូវលិខិតនេះ នឹងដើម្បីអញ្ជើញលោកអ្នកឲ្យចូលរួមនៅក្នុងកម្មវិធី។ ព័ត៌មានផ្ទាល់ខ្លួនរបស់លោកអ្នក ដូចជាឈ្មោះរបស់លោកអ្នក សេចក្តីលំអិតនៃព័ត៌មានសំរាប់ទាក់ទង អាយុ ភេទ លេខមេឌីឃែរ លទ្ធផលនៃការធ្វើតេស្តពិនិត្យមើល និងឈ្មោះវេជ្ជបណ្ឌិតរបស់លោកអ្នក ត្រូវបានការពារដោយបទបញ្ញតិនៅក្រោមច្បាប់ព័ត៌មានឯកជនឆ្នាំ១៩៨៨។ ជម្ងឺមហារីកពោះវៀន ប្រសិនបើមាននោះ អាចបង្ហាញឲ្យឃើញនូវរោគសញ្ញាយ៉ាងតិចតួចពីដំបូង។ ហេតុដូច្នេះ សូមចំណាយពេលដើម្បីអានព័ត៌មាននៅក្នុងកញ្ចប់អញ្ជើញ នៅពេលលោកអ្នកបានទទួលវា ពីព្រោះថាការរកឃើញនៅពេលពីដំបូង គឺជាការការពារប្រសើរជាងគេដែលយើងត្រូវប្រយុទ្ធទប់ទល់នឹងជម្ងឺមហារីកពោះវៀនក្នុងពេលបច្ចុប្បន្ននេះ។

ប្រសិនបើលោកអ្នកកំពុងទទួលការព្យាបាលជម្ងឺមហារីកពោះវៀនរួចហើយ ឬមានលក្ខណៈរោគដែលវេជ្ជបណ្ឌិតរបស់លោកអ្នកស្នើថាលោកអ្នកអាចប៉ះពាល់ពីការចូលរួមនៅក្នុងកម្មវិធី លោកអ្នកអាចជ្រើសរើសមិនចូលរួម ឬផ្អាកពីការចូលរួមនៅក្នុងកម្មវិធីដោយបំពេញហ្វ៍ម Opt Off/Suspend (មិនចូលរួម/ផ្អាកមិនចូលរួម) មាននៅក្នុងកូនសៀវភៅព័ត៌មានដែលភ្ជាប់មកជាមួយនឹងកញ្ចប់អញ្ជើញ។

ខ្ញុំសង្ឃឹមថាលោកអ្នកនឹងជ្រើសរើសចូលរួមនៅក្នុងកម្មវិធីដ៏សំខាន់នេះ។

ដោយនូវសេចក្តីគោរព

សាស្ត្រាចារ្យ **John Horvath AO**

នាយកបុគ្គលិកផ្នែកវេជ្ជសាស្ត្រ

NBCSR XXX